# សេចក្ដីណែនាំស្ដីពី ការចារឹកអក្សរលើស្តូបមិត្តភាព កម្ពុជា-វៀតណាម នៅតាមរាជធានី-ខេត្ត

តេលេក្រាម | ឯកសារមន្ត្រីសាធារណៈ

Scan to Join!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ០១.សណន.

# សេចក្តីណែនាំ
## ស្តីពី
## ការថែរក្សានូវអត្ថន័យនៃសច្ចភាពជាប្រវត្តិសាស្ត្រលើស្តូបមិត្តភាពកម្ពុជា-វៀតណាមដែលបានសាងសង់ឡើងនៅតាមបណ្តារាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា

ចាប់តាំងពីទសវត្សរ៍៨០ រហូតមក ស្តូបមិត្តភាពកម្ពុជា-វៀតណាមត្រូវបានសាងសង់ឡើងជាបន្តបន្ទាប់នៅតាមរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជានិមិត្តរូប និងជាការចងចាំនូវទំនាក់ទំនងមិត្តភាព កិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគ្នាទៅវិញទៅមករវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ដែលជាប្រទេសជិតខាងនឹងគ្នា ក្នុងបុព្វហេតុនៃការនាំមកនូវសុខសន្តិភាពនៃប្រទេសនីមួយៗ។ ជាក់ស្តែង ក្នុងអំឡុងទសវត្សរ៍៦០-៧០ ព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជកិច្ចដឹកនាំរបស់ **ព្រះបរមរតនកោដ្ឋ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** បានចូលរួមជួយប្រទេសវៀតណាមក្នុងបុព្វហេតុនៃការបង្រួបបង្រួមជាតិនិងឯកភាពទឹកដីវៀតណាម ហើយនៅទសវត្សរ៍៧០-៨០ ប្រទេសវៀតណាមក៏បានចូលរួមជួយកម្ពុជាក្នុងបុព្វហេតុរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ។

ទោះបីជាយ៉ាងនេះក្តី ក៏កន្លងមកមានមជ្ឈដ្ឋានមួយចំនួនមិនទាន់មានការយល់ដឹងច្បាស់លាស់អំពីអត្ថន័យពិតប្រាកដនៃស្តូបមិត្តភាពកម្ពុជា-វៀតណាម និងបានធ្វើការបកស្រាយក្នុងន័យផ្សេងៗគ្នា ខុសពីការពិត និងសច្ចភាពជាប្រវត្តិសាស្ត្រ។ ទន្ទឹមនេះ ក៏មានអ្នកនយោបាយខ្លះបានប្រើប្រាស់ស្តូបមិត្តភាពកម្ពុជា-វៀតណាម ជាមូលដ្ឋានដើម្បីធ្វើការវាយប្រហារ អុជអាល ញុះញង់ បំបែកបំបាក់ទំនាក់ទំនង មិត្តភាព កិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជានិងវៀតណាម និងបំផុសបំផុលឱ្យមានការរើសអើងប្រកាន់ពូជសាសន៍រវាងប្រជាជាតិនិងប្រជាជននៃប្រទេសទាំងពីរថែមទៀត។

ដើម្បីថែរក្សាការពារនូវសច្ចភាពជាប្រវត្តិសាស្ត្រនៃការជួយឧបត្ថម្ភ គាំទ្រគ្នាទៅវិញទៅមករវាងប្រទេសទាំងពីរ (កម្ពុជា-វៀតណាម) សំដៅបន្តពង្រឹងនិងលើកកម្ពស់ទំនាក់ទំនងកិច្ចសហ-

ប្រតិបត្តិការរវាងប្រទេសទាំងពីរដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីធានាបាននូវផលប្រយោជន៍ទាំងសង្ខាង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម៖

១).ប្រគល់ភារកិច្ចជូនរដ្ឋបាលរាជធានី-ខេត្តសហការជាមួយមន្ទីរ-អង្គភាពពាក់ព័ន្ធ ធ្វើការពិនិត្យ និងរៀបចំចារឹកនូវអត្ថន័យសច្ចភាពជាប្រវត្តិសាស្ត្រជាភាសាខ្មែរ ភាសាវៀតណាម និងភាសាអង់គ្លេស លើស្តូបមិត្តភាពកម្ពុជា-វៀតណាមដែលបានសាងសង់នៅតាមរាជធានី-ខេត្តនីមួយៗ ដោយឆ្លាក់តួអក្សរឱ្យបានច្បាស់ ដើម្បីឱ្យសាធារណជនអាចមើលឃើញនិងអានបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីណែនាំនេះ។ ទន្ទឹមនេះ បន្ទាប់ពីការរៀបចំចារឹកនូវអត្ថន័យខាងលើរួចរាល់ រដ្ឋបាលរាជធានី-ខេត្តត្រូវរៀបចំពិធីសម្ពោធនូវផ្ទាំងចារឹកនេះ ដើម្បីផ្សព្វផ្សាយជូនដល់សាធារណជនបានជ្រាបអំពីអត្ថន័យនៃស្តូបមិត្តភាពកម្ពុជា-វៀតណាម។

២).រដ្ឋបាលរាជធានី-ខេត្តនីមួយៗត្រូវធ្វើការគ្រប់គ្រង ថែរក្សា ការពារស្តូបមិត្តភាពកម្ពុជា-វៀតណាម ដែលបានសាងសង់នៅតាមរាជធានី-ខេត្តរបស់ខ្លួន។ ក្នុងករណីមានការជួសជុលកែលម្អស្តូបមិត្តភាពនេះ ត្រូវរក្សារចនាបទដើមដែលបានសាងសង់។

ទទួលបានសេចក្តីណែនាំនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ននានា និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-រដ្ឋបាលរាជធានី-ខេត្តទាំងអស់
-រាជកិច្ច
-ឯកសារកាលប្បវត្តិ



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

<u>**ឧបសម្ព័ន្ធ**</u>

ត្រូវចារឹកអក្សរនៅលើស្តូបមិត្តភាពកម្ពុជា-វៀតណាម ដែលបានសាងសង់រួចនៅតាមបណ្តារាជធានី-ខេត្ត ដែលមានខ្លឹមសារដូចខាងក្រោម៖

*«ស្តូបមិត្តភាពកម្ពុជា-វៀតណាមត្រូវបានសាងសង់ឡើងដើម្បីជាសក្ខីភាពនៃការដឹងគុណនិងការចងចាំចំពោះពលិកម្មរបស់ប្រជាជនកម្ពុជា ដើម្បីបុព្វហេតុនៃការបង្រួបបង្រួមនិងឯកភាពទឹកដីវៀតណាមក្នុងអំឡុងទសវត្សរ៍៦០-៧០ និងជាសក្ខីភាពនៃការដឹងគុណនិងការចងចាំចំពោះពលិកម្មរបស់កងទ័ព និងប្រជាជនវៀតណាម ដើម្បីបុព្វហេតុរំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ នៅទសវត្សរ៍៧០-៨០។»*

*"Tượng đài hữu nghị Campuchia-Việt Nam được xây dựng để bày tỏ sự tri ân và ghi nhớ đối với sự hy sinh của nhân dân Campuchia vì sự nghiệp hòa hợp và thống nhất đất nước Việt Nam trong suốt thập niên 60, 70 và bày tỏ sự tri ân và ghi nhớ đối với sự hy sinh của quân đội và nhân dân Việt Nam vì sự nghiệp giải phóng nhân dân Campuchia thoát khỏi chế độ diệt chủng Campuchia dân chủ vào thập niên 70, 80."*

*"The Cambodia-Vietnam Friendship Monument was built as a testimonial of gratitude for and in memory of the sacrifice of Cambodian people in the cause of Vietnam's territorial unification during the 60s-70s, and the sacrifice of Vietnamese Army and People in the liberation of Cambodian people from the genocidal regime of Democratic Kampuchea in the 70s-80s."*